# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ELECTRICITE DU CAMBODGE

**អគ្គិសនីកម្ពុជា**

លេខ: ៥៩១៤ អសណ.អក.រប

## សេចក្ដីជូនដំណឹង
## ស្ដីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជាត្រូវការជ្រើសរើសបុគ្គលិក សរុបចំនួន០៧រូប ដើម្បីចូលបម្រើការងារនៅតាមបណ្ដាអង្គភាព-អគ្គិសនីខេត្ត ដូចខាងក្រោម :

*- **លក្ខណៈសម្បត្តិបេក្ខជន** :

១- អគ្គិសនីព្រៃវែង : បុគ្គលិកគណនេយ្យ ចំនួន០១រូប :

- បេក្ខជនទាំងពីរភេទ មានអាយុចាប់ពី១៨ឆ្នាំ ដល់ ៣៥ឆ្នាំ
- បៀវត្សរ៍ផ្ដល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ០៣ខែ ទទួលបាន៩០%
- កម្រិតជំនាញ : បញ្ចប់ការសិក្សាបរិញ្ញាបត្រគណនេយ្យឡើងទៅ

២- អគ្គិសនីត្បូងឃ្មុំ : ភ្នាក់ងារជំរឿនអន្តរាគមន៍កាត់និងភ្ជាប់ចរន្ត សាខាពញាក្រែក និង ភ្នាក់ងារចែកវិក្កយបត្រ សាខាមេមត់ សរុបចំនួន០២រូប:

- បេក្ខជនភេទប្រុស មានអាយុចាប់ពី១៨ឆ្នាំ ដល់ ៣៥ឆ្នាំ
- បៀវត្សរ៍ផ្ដល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ០៣ខែ ទទួលបាន៩០%
- កម្រិតជំនាញ : បញ្ចប់ការសិក្សាសញ្ញាប័ត្រមធ្យមបច្ចេកទេសអគ្គិសនីឡើងទៅ

៣- មជ្ឈមណ្ឌលបញ្ជា : បុគ្គលិកប្រចាំការចុះពិនិត្យជួសជុលនិងរកកំហូចកាប សរុបចំនួន០៤រូប:

- បេក្ខជនភេទប្រុស មានអាយុចាប់ពី១៨ឆ្នាំ ដល់ ៣៥ឆ្នាំ
- បៀវត្សរ៍ផ្ដល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ០៣ខែ ទទួលបាន៩០%
- កម្រិតជំនាញ : បញ្ចប់ការសិក្សាសញ្ញាប័ត្រមធ្យមបច្ចេកទេសអគ្គិសនីឡើងទៅ និងមានប័ណ្ណបើកបររថយន្តប្រភេទ"ខ"

*- **ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅអគ្គិសនីកម្ពុជាបេក្ខជនត្រូវទាញយក(Download) ដោយផ្ទាល់ពីក្នុងគេហទំព័ររបស់អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុចព័ត៌មានវិជ្ជាជីវៈ ដោយចុចលើពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅអគ្គិសនីកម្ពុជា។**

*- បេក្ខជនត្រូវបំពេញពាក្យសុំចូលបម្រើការងារ និងត្រូវអញ្ជើញមកដាក់ពាក្យប្រឡងដោយផ្ទាល់ខ្លួន និងភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនច្បាប់ដើមមកជាមួយ។ ករណីបេក្ខជនមិនបានអញ្ជើញមកដាក់ពាក្យដោយផ្ទាល់ទេ អគ្គិសនីកម្ពុជាមិនទទួលពាក្យជូនឡើយ។

*- បេក្ខជនដាក់ពាក្យត្រូវពាក់ម៉ាស់ និងរក្សាគម្លាតសុវត្ថិភាពឲ្យបានត្រឹមត្រូវ។

*- **បេក្ខជនត្រូវមកដាក់ពាក្យ និងភ្ជាប់មកជាមួយនូវ** :

| | |
|---|---|
| - ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារ នៅអគ្គិសនីកម្ពុជា | ចំនួន០១ច្បាប់ |
| - ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ x ៦ | ចំនួន០១ច្បាប់ |
| - កិច្ចសន្យា សម្រាប់បំពេញពាក្យសុំចូលបម្រើការងារ និងកិច្ចសន្យាការងារ | ចំនួន០១ច្បាប់ |
| - សលាកប័ត្របេក្ខជន | ចំនួន០១ច្បាប់ |
| - ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ និងសញ្ញាប័ត្រជំនាញ | ចំនួន០១ច្បាប់ |
| - តារាងពិន្ទុ(TRANSCRIPT) | ចំនួន០១ច្បាប់ |
| - ច្បាប់ដើម និងច្បាប់ចម្លងនៃអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន | ចំនួន០១ច្បាប់ |
| - ច្បាប់ចម្លងប័ណ្ណបើកបររថយន្ត (សម្រាប់មជ្ឈមណ្ឌលបញ្ជា) | ចំនួន០១ច្បាប់ |

*- ចំពោះបែបបទមួយចំនួនទៀត ដូចមានចែងក្នុងឧបសម្ព័ន្ធ I នៃលក្ខន្តិកៈបុគ្គលិកអគ្គិសនីកម្ពុជា បេក្ខជនប្រឡងជាប់ មានកាតព្វកិច្ចបំពេញបន្ថែម។

*- **ទីកន្លែងទទួលពាក្យ** : សាលប្រជុំនាយកដ្ឋានរដ្ឋបាល នៅកីឡដ្ឋានបាល់ទាត់អគ្គិសនីកម្ពុជា(អតីតរោងចក្រអគ្គិសនីទី៤)។

ចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២ រៀងរាល់ថ្ងៃធ្វើការ

- **ពេលព្រឹក** ចាប់ពីម៉ោង០៨:០០ ដល់ម៉ោង១១:៣០ **ពេលល្ងាច** ចាប់ពីម៉ោង១៤:០០ ដល់ម៉ោង១៧:០០

*- **ព័ត៌មានផ្សេងៗ**:សូមអញ្ជើញមកទាក់ទង ការិយាល័យរដ្ឋបាល ទីស្នាក់ការកណ្តាល អគ្គិសនីកម្ពុជា ឬ តាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១។

ថ្ងៃ ចន្ទ ៧រោច ខែ អស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ២០២២

**ជ.រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**

**អគ្គនាយកអគ្គិសនីកម្ពុជា**

**អគ្គនាយករង**

ELECTRICITE DU CAMBODGE

**អេង_គន្ធា**

**បញ្ជាក់**

- សេចក្តីជូនដំណឹងនេះ ធ្វើការផ្សព្វផ្សាយជាផ្លូវការតាមរយៈគេហទំព័ររបស់អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុច " ព័ត៌មានវិជ្ជាជីវៈ " ។